# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ ខ្មែរត្រូវរួបរួមគ្នាប្រឆាំងនឹងសត្រូវថៃឈ្លានពានទឹកដីខ្មែរ

www.hoksavann.org

ថ្ងៃទី១២ កុម្ភៈ ២០១១



រាជរដ្ឋាភិបាលខ្មែរបានសាកល្បងចរចាជាទ្វេភាគីជាមួយរដ្ឋាភិបាលថៃ ដើម្បីដោះស្រាយបញ្ហាមហិច្ឆិតារបស់ថៃ ដែលចង់បានដីខ្មែរនៅក្បែរប្រាសាទព្រះវិហារទំហំ៤.៦គម២ ។ ការចរចានោះ ដែលបានចាប់ផ្តើមតាំងពីថ្ងៃ១៥ កក្កដា ២០០៨ រហូតមកដល់ឆ្នាំ២០១១ គ្មានបានផលអ្វីឡើយ ។ មិនត្រឹមតែមិនបានផលទេ ថៃបានវាយប្រហារប្រទេសកម្ពុជាជាច្រើនលើកជាពិសេសថ្ងៃទី៤, ៥ និង៦ កុម្ភៈ ២០១១ ថៃបានធ្វើសង្គ្រាមជាមួយប្រទេសកម្ពុជាដោយចេញមុខដោយផ្ទោងគ្រាប់បែកធុនធ្ងន់ ដែលធ្វើឲ្យខូចខាតប្រាសាទព្រះវិហារជាច្រើនកន្លែង វត្តកែវសិក្ខាគីរីស្វារៈក៏ត្រូវខូចខាត ។ មិនតែប៉ុណ្ណោះការឈ្លានពានរបស់ថៃ បានធ្វើឲ្យពលរដ្ឋនិងទាហានខ្មែរត្រូវរបួសនិងស្លាប់អស់ជាច្រើន ហើយប្រជាពលរដ្ឋខ្មែរជាច្រើនរាប់ម៉ឺននាក់បានភៀសខ្លួនចេញពីកន្លែងកើតហេតុ ។

រាជរដ្ឋាភិបាលបានប្តូរគំនិតពីការចរចាជាមួយថៃជាទ្វេភាគី មកជាទ្វេភាគីរួមជាមួយអ្នកទី៣ ។ ជាពិសេស រាជរដ្ឋាភិបាលខ្មែរបានប្តឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អំពីករណីដែលថៃធ្វើសង្គ្រាមជាមួយប្រទេសកម្ពុជា ដើម្បីឲ្យអង្គការនេះធ្វើអន្តរាគមន៍ កុំឲ្យថៃបន្តសង្គ្រាមនេះជាបន្តទៅទៀត ។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានសំរេចប្រជុំគ្នានៅថ្ងៃច័ន្ទទី១៤ កុម្ភៈ ២០១១នេះ ដោយមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ ថៃ និងឥណ្ឌូណេស៊ី ដើម្បីដោះស្រាយបញ្ហាសង្គ្រាមរវាងខ្មែរនិងថៃ ។

ចំពោះយើងក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលខ្មែរមានទស្សនៈថា ការចរចាជាទ្វេភាគីជាមួយថៃ ពិតជាពុំបានផលអ្វីឡើយ ត្រូវតែប្តឹងទៅអង្គការសហប្រជាជាតិ ទៅតុលាការក្រុងឡាអេ ឬសុំបើកប្រជុំឡើងវិញនូវកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជានៅថ្ងៃ២៣ តុលា ១៩៩១ នៅទីក្រុងប៉ារីស ។ រាជរដ្ឋាភិបាលខ្មែរពេលនោះពុំយល់ស្របតាមទស្សនៈនេះឡើយ ចង់សាកល្បងចរចាជាមួយថៃជាមុនសិន ។ ការចរចាអស់រយៈពេលជាង២ឆ្នាំ ទើបឃើញយ៉ាងច្បាស់លាស់ថា ថៃគ្មានសុឆន្ទៈជាមួយខ្មែរឡើយ ក្រៅតែពីចង់បានដីខ្មែរបន្តទៅទៀតប៉ុណ្ណោះ ។ ឬក៏រដ្ឋាភិបាលខ្មែររង់ចាំមើលកំហុសថៃ ពេលណាថៃប្រើអំពើហឹង្សាធ្វើសង្គ្រាមមកលើប្រទេសកម្ពុជា ទើបចាប់ប្តឹងថៃ ដើម្បីឲ្យពិភពលោកយកចិត្តទុកដាក់ដោះស្រាយ ? ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក្នុងពេលនេះសកម្មភាពរបស់រាជរដ្ឋាភិបាលស្របតាមយោបល់ខាងលើនេះហើយ គ្រាន់តែធ្វើសំណូមពរថា ដើរទៅមុខត្រូវតែដើរទៅមុខ កុំថយក្រោយ កុំជឿថៃ បែរមកចរចាជាមួយថៃជាទ្វេភាគីវិញឡើយ ។

តាមប្រវត្តិសាស្ត្រ ថៃដែលពីដើមហៅថាសៀម បានកើតជាប្រទេសនៅចុងសតវត្សរ៍ទី១៣ ដើមសតវត្សរ៍ទី១៤ ជាកុលសម្ព័ន្ធរបស់ចិនប៉ែកខាងត្បូង គឺកើតក្រោយប្រាសាទព្រះវិហាររបស់ខ្មែរដែលថៃចង់បានជាច្រើនសតវត្សរ៍ ។ ទឹកដីថៃគ្មានទេ ប៉ុន្តែជាតិនេះដើររាតត្បាតដណ្តើមយកទឹកដីពីជាតិដទៃ ដូចបច្ចុប្បន្ននេះរំលោភយកទឹកដីខ្មែរ ទឹកដីលាវ ទឹកដីភូមាជាដើមដោយកម្លាំងទ័ព ។ ថៃតែងតែធ្វើសង្គ្រាមជាមួយខ្មែរជាញឹកញាប់ដើម្បីពង្រីកទឹកដី ព្រះករុណាព្រះបាទនរោត្តមបានសុំឲ្យបារាំងជួយការពារប្រទេសកម្ពុជាក្នុងឆ្នាំ១៨៦៣ ពីការរំលោភឈ្លានពានពីប្រទេសថៃប៉ែកខាងលិច និងពីប្រទេសវៀតណាមប៉ែកខាងកើត ។ សន្ធិសញ្ញាឆ្នាំ១៩០៤,១៩០៧រវាងបារាំងនិងថៃអំពីការកំណត់ព្រំដែនដីគោកខ្មែរ-ថៃទុកជាមូលដ្ឋានសំខាន់ណាស់ ដែលធ្វើឲ្យខ្មែរឈ្នះក្តីប្រាសាទព្រះវិហារនៅក្រុងឡាអេក្នុងឆ្នាំ១៩៦២ ។ តុលាការក្រុងឡាអេបានបញ្ជាឲ្យថៃដកទ័ពរបស់ខ្លួនចេញពីព្រះវិហារ ហើយវត្ថុដែលថៃប្រមូលយកទៅត្រូវប្រគល់ឲ្យខ្មែរវិញ ។ ចាប់ពីពេលនោះមក ថៃមិនបានតវ៉ាអ្វីឡើយ ទើបតែនាយករដ្ឋមន្ត្រីថៃអាភីស៊ីតនៃគណបក្សប្រជាធិបតេយ្យ គូរផែនទីក្លែងក្លាយជាឯកតោភាគី បញ្ចូលដី៤.៦គម២ នៅក្បែរព្រះវិហារថាជារបស់ខ្លួន រហូតបង្កើតចំបាំងជាមួយប្រទេសកម្ពុជា ចង់កាន់កាប់ដីនោះនិងវត្តកែវសិក្ខាគីរីស្វារៈដោយកម្លាំងទ័ព ។ អំពើឈ្លានពាននេះថៃត្រូវបរាជ័យ ដោយទ័ពស្នេហាជាតិរបស់ប្រទេសកម្ពុជា ហើយថៃត្រូវចោទថា បានប្រើគ្រាប់បែកចង្កោម ដែលអន្តរជាតិហាមឃាត់ថែមទៀត ។

ថៃមិនចង់ឲ្យអ្នកទី៣ ជាពិសេសអង្គការសហប្រជាជាតិចូលធ្វើអន្តរាគមន៍ ព្រោះថៃគ្មានសំអាងអ្វីឲ្យរឹងមាំ ក្នុងការទាមទារដីនៅក្បែរប្រាសាទព្រះវិហារ ក្រៅពីប្រឌិតផែនទីក្លែងក្លាយរបស់ខ្លួន ។ មួយទៀត ថៃគ្មានសិទ្ធិជំទាស់ក្នុងការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកឡើយ ព្រោះជាប្រាសាទរបស់ខ្មែរ ។ គួរយកជាមេរៀន ការពិសោធន៍របស់ព្រះករុណាសម្តេចនរោត្តម-សីហនុ ដែលកាលនោះព្រះអង្គនៅជាប្រមុខរដ្ឋ បានចរចាជាមួយថៃអំពីប្រាសាទព្រះវិហារអស់ពេលជាច្រើនឆ្នាំ តែពុំបានលទ្ធផលអ្វីឡើយ ទើបឆ្នាំ១៩៥៩ ព្រះអង្គដាក់ពាក្យប្តឹងទៅតុលាការក្រុងឡាអេឆ្នាំ១៩៦២ ទើបតុលាការនេះកាត់សេចក្តីឲ្យខ្មែរឈ្នះ ។ បានន័យសេចក្តីមកថា ថៃជាមេចោរ ការចរចាជាមួយចោរប្លន់ទឹកដីពិតជាគ្មានបានផលឡើយ ត្រូវតែឲ្យច្បាប់កាត់សេចក្តីកាត់ទោសមេចោរនេះតាមគតិយុត្តិធម៌ ។ តាមផ្លូវច្បាប់ ខ្មែរពិតជាមានជ័យជំនះ ព្រោះខ្មែរមានគ្រឿងសំអាងយ៉ាងរឹងមាំដូចសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤, ១៩០៧ តុលាការក្រុងឡាអេដែលកាត់ឲ្យខ្មែរឈ្នះក្តីជាដើម ។ ដូច្នេះខ្មែរគ្រប់គណបក្សនយោបាយ សង្គមស៊ីវិល ត្រូវរួបរួមសាមគ្គីគ្នាឲ្យមានឯកភាពជាតិ ប្រឆាំងនឹងសត្រូវថៃឈ្លានពានទឹកដីខ្មែរ ។៚